**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
សំណុំរឿងលេខ ១៦០
ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣
សាលដីកាលេខ ៧៧៥ VIII
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

# សាលដីកា
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣
ដែលមានសមាសភាពអង្គជំនុំជម្រះ ដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន
២-ឯកឧត្តម [redacted] ជាចៅក្រម
៣-ឯកឧត្តម [redacted] ជាចៅក្រម
៤-ឯកឧត្តម [redacted] ជាចៅក្រម
៥-លោកជំទាវ [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**
លោកជំទាវ [redacted]

**ក្រឡាបញ្ជីសវនាការ**
លោកស្រី [redacted]

**តំណាងមហាអយ្យការ**
ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ហ៊ុត ឈ្មោះ [redacted]សែ ឈ្មោះ [redacted]ម៉ាប់ និងឈ្មោះ[redacted]អាត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ព្រ.ទ ក្រIV (ខ.ណ) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមាន៖

**ជនជាប់ចោទ** (អ្នកប្តឹងសាទុក្ខ)

១-ឈ្មោះ[redacted]ម៉ាប់ ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅ ប[redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ[redacted]ស្លាប់" ប្រពន្ធឈ្មោះ[redacted]ទឹម មានកូន ០៥នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

២-ឈ្មោះ [redacted] ហ៊ុត ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅ [redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោ[redacted]ស់" ប្តីឈ្មោះ [redacted]ណាត មានកូន ០៤នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៣-ឈ្មោះ [redacted] ទូច ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិពងទឹក ឃុំកណ្តុរជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាម[redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] ពុត "រស់" ម្តាយឈ្មោ[redacted] អូន "រស់" ប្រពន្ធឈ្មោ[redacted]មានកូន ០២នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៤-ឈ្មោះ [redacted]សៃ ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅ [redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោ[redacted]សៀង "ស្លាប់" ម្តាយឈ្មោះ[redacted] យឿន "ស្លាប់" ប្រពន្ធឈ្មោះ[redacted]ធិ មានកូន ០៥នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៥-ឈ្មោះ [redacted] អាត ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ[redacted]ស្រួច "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted]ល័ក្ខ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

**ជាប់ចោទពីបទ** ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅចំណុចភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ កាលពីខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល។

លោក [redacted]ក័ណ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ាប់ ឈ្មោះ[redacted]ទូច ឈ្មោះ [redacted]សៃ និងឈ្មោះ[redacted]អាត ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted]ម្យ ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted]គីរម្យ បានទិញដីទំហំជាងមួយរយហិកតាដែលស្ថិតនៅភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ពីឈ្មោះ[redacted]ងឹម ដោយមានកិច្ចសន្យាទិញដីចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩។ ក្រោយមកឈ្មោះ [redacted]គីរម្យ បានដាំដំណាំស្វាយចន្ទី និងដំណាំស្រូវផងដែរ។ ស្រាប់តែនៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៩ មានជនជាប់ចោទឈ្មោះ [redacted]ម៉ាប់ ឈ្មោះ[redacted]សៃ ឈ្មោះ [redacted]ទូច ឈ្មោ[redacted] ហ៊ុត និងឈ្មោះ[redacted]អាត បានយកត្រាក់ទ័រមកភ្ជួរដី និងបាញ់ថ្នាំស្មៅ រួចបោកស្រូវ និងដាំកូនស្វាយចន្ទីនៅលើដីរបស់ជនរងគ្រោះឈ្មោះ [redacted]គីរម្យ ថែមទៀត។

- **បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៨០០ "ខ" ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖**

១-ផ្ដន្ទាទោសលើ៖

ក.ឈ្មោះ[redacted]ម៉ាប់ ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ខ.ឈ្មោះ[redacted]ហ៊ីត ភេទស្រី អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

គ.ឈ្មោះ[redacted]ទូច ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ឃ.ឈ្មោះ[redacted]សែ ភេទប្រុស អាយុ ៥១ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ង.ឈ្មោះ [redacted] អាត ភេទប្រុស អាយុ ៤៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

ពីបទ **ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិចឹង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ កាលពីខែកក្កដា ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល។ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ម៉ាប់, ជនជាប់ចោទឈ្មោះ [redacted]ហ៊ីត, ជនជាប់ចោទឈ្មោះ [redacted]ទូច, ជនជាប់ចោទឈ្មោះ [redacted]សែ និងជនជាប់ចោទឈ្មោ[redacted]អាត និងចំពោះមុខជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោ[redacted]គីរម្យ។

- **បានឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ៩៧ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ របស់លោក [redacted] សោភ័ណ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]ម៉ាប់ ឈ្មោ[redacted]ទូច ឈ្មោ[redacted]សែ ឈ្មោះ [redacted] ហ៊ីត និងឈ្មោ[redacted]អាត ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៨០០ “ខ” ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

- **បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ព្រ.ឧ ក្រIV (ខ.ណា) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖**

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ របស់លោកមេធាវី[redacted]សោភ័ណ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយខុសនិងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨០០ "ខ" ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃអង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ឈ្មោះ [redacted] ហ៊ីត ឈ្មោះ [redacted] ទូច ឈ្មោះ [redacted] សែ និងឈ្មោះ [redacted] អាត និងកំបាំងមុខជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភីរម្យ។

ទុកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

- **បានឃើញ** បណ្ដឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ហ៊ីត ឈ្មោះ [redacted] សែ ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] អាត ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ព្រ.ទ ក្រIV (ខ.ណ) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការនៅតុលាការកំពូល

-ចៅក្រមរបាយការណ៍អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំថា តាមការបង្ហាញរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ គឺមិនមែនជាភស្តុតាងដាក់បន្ទុកនោះទេ គឺជាភស្តុតាងប្រយោល ម្យ៉ាងទៀតដីទំនាស់ក៏មិនមានទីតាំងច្បាស់លាស់ មិនដឹងជាកម្មសិទ្ធិរបស់រដ្ឋ ឬ បុគ្គលណាមួយឡើយ។ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាទៅលើធាតុផ្សំនៃបទល្មើស។ ហេតុដូច្នេះតំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលឱ្យទទួលបណ្ដឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ទូច ឈ្មោះ [redacted] ហ៊ីត ឈ្មោះ [redacted] សែ ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] អាត ។ សូមក្រុមប្រឹក្សាមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-លោក [redacted] សោភ័ណ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា ការសម្រេចរបស់សាលាឧទ្ធរណ៍គឺជាការសន្មតថា ដើមបណ្ដឹងរដ្ឋប្បវេណីតាំងខ្លួនជាជនរងគ្រោះ គឺជាអ្នកកាន់កាប់ដោយសុចរិត តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល ដែលផ្ទុយនឹងសំណុំរឿង។ ខ្លួនបានលើកឡើងពីវិការៈភាពជាម្ចាស់របស់ដើមបណ្ដឹងរដ្ឋប្បវេណីហើយ តែលោកមេភូមិបានបដិសេធ។ ខ្លួនបានដាក់លិខិតបញ្ជាក់អត្តសញ្ញាណ តែតុលាការពុំបានពិចារណាទេ។ ពុំមានអ្នកណាបញ្ជាក់ថាឈ្មោះ ភារម្យ ជាអ្នកកាន់កាប់ដីនោះទេ ដីនេះគឺជាដីមិនទាន់ចុះបញ្ជី។ ការកាន់កាប់បែបប្រពៃណីគឺអ្នករស់នៅមានសិទ្ធិកាន់កាប់អាស្រ័យផល តែពុំមានសិទ្ធិលក់ទេ អ្នកគាត់បានទៅសុំមេភូមិតាមទំនៀមទំលាប់។

សំណូមពរ សូមតុលាការពិចារណាតាមមាត្រា ១៤ និងមាត្រា ២៣ នៃច្បាប់ភូមិបាល។

-ជនជាប់ចោទឈ្មោ[redacted] ទូច ឈ្មោ[redacted]ហ៊ុត ឈ្មោះ[redacted]ស ឈ្មោះ[redacted]ម៉ាប់ និងឈ្មោះ[redacted] **អាត** បានឆ្លើយថា ដីនោះជាដីចាស់ជំនាន់យាយតាមក ដីស្រែចាស់ទុកចោលប្រហែល១០ឆ្នាំ ហើយទៅធ្វើដីផ្សេង។ ពួកខ្លួនពុំបានភ្ជួរ បាញ់ថ្នាំនៅលើដីនោះទេ។ ឈ្មោះ ព្រំ ភីរម្យ បានទិញដីនៅជិតដីដែលខ្លួនធ្វើនោះ ហើយបែរជាមកធ្វើប្លង់លើដីដែលពួកខ្លួនកំពុងកាន់កាប់។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ[redacted] ទូច ឈ្មោះ[redacted] ហ៊ុត ឈ្មោះ[redacted] សៃ ឈ្មោះ[redacted]ម៉ាប់ និងឈ្មោះ[redacted] **អាត** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចយកមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-យល់ឃើញថា** សាលាឧទ្ធរណ៍ត្បូងឃ្មុំបានទទួលស្គាល់ថា ជនជាប់ចោទមានពិរុទ្ធភាពពីបទ **ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល ដោយសាលាឧទ្ធរណ៍យល់ឃើញថា “ជនជាប់ចោទទាំង០៥នាក់ខាងលើ ពិតជាបានធ្វើការដាំដំណាំអាស្រ័យផលនៅលើដីរបស់ដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដមែន ហើយដីនេះទៀតសោត ដើមបណ្តឹងរដ្ឋប្បវេណីបានគ្រប់គ្រងតាមរយៈកិច្ចសន្យាទិញដីចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ដោយផ្អែកតាមពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤៤៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ដីនោះដែលមានទំហំ បណ្តោយ ២០០០ ម៉ែត្រ ទទឹង ១៥០ម៉ែត្រ ចេញដោយមេឃុំឃ្មឹម”។ ចំពោះករណីនេះ តុលាការកំពូលពិនិត្យឃើញថា ៖

-មាត្រា ២៥៣ នៃច្បាប់ភូមិបាលចែងថា *ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០រៀល ដល់ ២៥.០០០.០០០រៀល ឬ/និងដាក់ពន្ធនាគារពី ៦ខែ ដល់ ២ឆ្នាំ ដោយពុំទាន់គិតបញ្ចូលនូវទោសប្រព្រឹត្តអំពើហិង្សាប្រឆាំងមនុស្ស។* យោងតាមបញ្ញត្តិខាងលើនេះ ការប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់គឺជាធាតុផ្សំមួយដ៏សំខាន់នៃបទល្មើស។

-នៅក្នុងរឿងក្តីនេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ដោយផ្អែកលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ[redacted]រម្យ ថា “ជនជាប់ចោទបានចូលមកក្នុងព្រំដីរបស់ឈ្មោ[redacted]ភីរម្យ ដែលមានប្រឡាយក្រវ៉ាត់ព្រំដី

និងបានយកត្រាក់ទ័រមកភ្ជួរ និងបាញ់ថ្នាំស្មៅ រួចបាចស្រូវ និងដាំកូនស្វាយចន្ទីនៅលើដីរបស់ឈ្មោះ [redacted]គីរម្យ លើទំហំ ៥៩.៨២ ហិកតា"។ អង្គហេតុដូចនេះមិនបង្កើតបានជាបទ ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាលនោះទេ ពីព្រោះថា មិនមានការប្រើប្រាស់អំពើហិង្សាណាមួយទៅលើអ្នកកាន់កាប់ដីដែលជាកម្មវត្ថុនៃវិវាទនោះឡើយ ដោយឈ្មោ[redacted]គីរម្យ អះអាងពីសិទ្ធិលើដីតាមលទ្ធកម្មមកពីការលក់ទិញ ចំណែកជនជាប់ចោទអះអាងថាជាដីរបស់រដ្ឋ ដោយខ្លួនមិនបានដឹងថាជាដីរបស់អ្នកណាទេនៅពេលចូលមកកាប់រាន ដែលការណ៍នេះគឺជាវិវាទពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើដីទំនាស់ ដែលជាវិវាទរដ្ឋប្បវេណី។ ហេតុដូច្នេះ តាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយគ្មានបង្វិលសំណុំរឿង។

**៣-យល់ឃើញថា** ការដែលតំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា "តាមការបង្ហាញរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ត្បូងឃ្មុំ គឺមិនមែនជាភស្តុតាងដាក់បន្ទុកនោះទេ គឺជាភស្តុតាងប្រយោល ម្យ៉ាងទៀត ដីទំនាស់ក៏មិនមានទីតាំងច្បាស់លាស់ មិនដឹងជាកម្មសិទ្ធិរបស់រដ្ឋ ឬ បុគ្គលណាមួយឡើយ" គឺមានភាពត្រឹមត្រូវហើយ ដូចក្នុងសំអាងហេតុខាងលើរបស់តុលាការកំពូល។

**៤-យល់ឃើញថា** បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុនៃបណ្ដឹងសាទុក្ខ តាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់ចំណុច "ការអនុវត្តខុសច្បាប់"។

**៥-យល់ឃើញថា** សាលដីកាលេខ ៤៥ ព្រ.ទ ក្រIV (ខ.ណ) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលបានសម្រេចសេចក្ដីមកនេះ មិនត្រឹមត្រូវតាមច្បាប់ទេ។

## ហេតុដូច្នេះសម្រេច

១-ទទួលបណ្ដឹងសាទុក្ខលេខ ០៨ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោ[redacted] ទូច ឈ្មោះ[redacted]ហ៊ឹត ឈ្មោះ [redacted]សែ ឈ្មោះ[redacted]ម៉ាប់ និងឈ្មោះ [redacted]អាត ។

២-បដិសេធសាលដីកាលេខ ៤៥ ព្រ.ទ ក្រIV (ខ.ណ) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

៣-ឱ្យជនជាប់ចោទឈ្មោ[redacted]ម៉ាប់ ភេទប្រុស អាយុ ៤៥ឆ្នាំ ឈ្មោ[redacted]ហ៊ឹត ភេទស្រី អាយុ ២៥ឆ្នាំ ឈ្មោះ[redacted]ទូច ភេទប្រុស អាយុ ២៥ឆ្នាំ ឈ្មោ[redacted]សែ ភេទប្រុស អាយុ ៥១ឆ្នាំ និងឈ្មោះ[redacted]អាត ភេទប្រុស អាយុ ៤៧ឆ្នាំ រួចខ្លួនពីការចោទប្រកាន់ពីបទ **ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណ[redacted]ស្រុកស្នួល ខេត្តក្រចេះ កាលពីខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០២៣។

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

លោកជំទាវ [redacted] ជាចៅក្រម

លោកស្រី [redacted] ជាក្រឡាបញ្ជី

---

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។**

ថ្ងៃអង្គារ ៦រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃអង្គារ ៦រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]